## ព័ត៌មានសំខាន់ទាក់ទងនឹង
## ការជំនុំជម្រះសំណុំរឿង

សំណុំរឿងគ្រួសាររបស់អ្នកត្រូវបានកំណត់ពេលសម្រាប់ការជំនុំជម្រះ (case management conference)។ មេធាវីការពារក្តីរំងគូភាគីត្រូវបានតម្រូវឲ្យចូលរួមក្នុងការជំនុំជម្រះនេះ លុះត្រាណាតែ៖

- *លិខិតបញ្ជាក់ជំនួសឲ្យការជំនុំជម្រះ (Certificate in Lieu of Conference)* (ទម្រង់បែបបទ FM-054) ត្រូវបានដាក់ទៅតុលាការមុនកាលបរិច្ឆេទជំនុំជម្រះ (ទម្រង់បែបបទនេះមាននៅគេហទំព័រផ្នែកយុត្តិធម៌ *(Judicial Branch)* តាមអាសយដ្ឋាន៖ http://courts.maine.gov/fees_forms/forms ឬការិយាល័យក្រឡាបញ្ជីតុលាការមណ្ឌលណាមួយរបស់រដ្ឋ Maine។ ទម្រង់បែបបទនេះអាចដាក់ទៅតុលាការបាន តែក្នុងករណីដែលគូភាគីយល់ព្រមលើការរៀបចំចាត់ចែងជាបណ្តោះអាសន្នសម្រាប់កូនៗប៉ុណ្ណោះ)។
- ការជំនុំជម្រះអាចត្រូវបានពន្យារពេលដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃរដ្ឋ Maine 110A(3)(A)(ii)។ ឬ
- គូភាគីយល់ព្រមចំពោះការកែសម្រួលនៃសាលក្រម ឬសេចក្តីបង្គាប់ដែលមានស្រាប់ និងដាក់លិខិតស្នាមសមរម្យទៅតុលាការមុនកាលបរិច្ឆេទជំនុំជម្រះ។

បញ្ហាខាងក្រោមនឹងត្រូវពិភាក្សានៅក្នុងការជំនុំជម្រះ ហើយសេចក្តីបង្គាប់មួយអាចនឹងត្រូវបានចេញដោយតុលាការនាពេលនោះ ឬនៅសវនាការបន្ទាប់ បើទោះបីជាសំណើសុំការអនុគ្រោះបណ្តោះអាសន្នមិនទាន់បានដាក់ទៅតុលាការយ៉ាងណាក្តី។

1. ការរៀបចំចាត់ចែងជាបណ្តោះអាសន្នសម្រាប់កូនៗ គិតទាំងកន្លែងរស់នៅ ទំនាក់ទំនងឪពុក/ម្តាយ/កូន ធានារ៉ាប់រងសុខភាព និងប្រាក់ឧបត្ថម្ភកូន ទំនួលខុសត្រូវបណ្តោះអាសន្នក្នុងការសងបំណុលជាគ្រា; និងប្រាក់ឧបត្ថម្ភសហព័ទ្ធ (ប្តី/ប្រពន្ធ) បណ្តោះអាសន្ន (បើមាន)។ *អ្នកត្រូវតែដាក់ទម្រង់បែបបទ FM-050 សេចក្តីបញ្ជាក់អះអាងពីប្រាក់ឧបត្ថម្ភកូន។ ការដាក់ទម្រង់នេះមិនត្រូវលើសពី 03 ថ្ងៃមុនការជំនុំជម្រះនោះទេ។*
2. ចំណុចវិវាទ
3. កាលកំណត់សម្រាប់បញ្ជូនសំណុំរឿងសម្រាប់ការដោះស្រាយ ការផ្លាស់ប្តូរព័ត៌មាន (ការប្តូរឯកសារសំណុំរឿងរវាងគូក្តី និងការសម្រុះសម្រួល។
4. ការបង់ថ្លៃនានា រួមទាំងថ្លៃសម្រុះសម្រួលនៅតុលាការ និងថ្លៃមេធាវីណាមួយ។

### អ្នកអាចនឹងត្រូវបានបង្គាប់ឲ្យចូលរួមការសម្រុះសម្រួល
### សូមចូលទៅកាន់ការជំនុំជម្រះដោយត្រៀមខ្លួនបង់ចំណែករបស់អ្នកលើថ្លៃសម្រុះសម្រួល

5. កាលបរិច្ឆេទ និងម៉ោងសម្រាប់សវនាការបន្ទាប់របស់តុលាការ។ **បើភាគីម្ខាងអវត្តមាន ឬបើសំណុំរឿងមានការពាក់ព័ន្ធនឹងការបង្កើត ឬការអនុវត្តកាតព្វកិច្ចផ្តល់ប្រាក់ឧបត្ថម្ភកូន សវនាការមួយអាចនឹងបើកនៅថ្ងៃជំនុំជម្រះ។**

6. ការបញ្ជូនទៅចៅក្រម. **នៅពេលដែលសិទ្ធិ និងទំនួលខុសត្រូវរបស់មេបាគឺជាចំណុចវិវាទ គូភាគីអាចមានសិទ្ធិប្រើប្រាស់សិទ្ធិរបស់ខ្លួនស្នើឲ្យចៅក្រមកំណត់សិទ្ធិ និងទំនួលខុសត្រូវមេបាបណ្ដោះអាសន្ន។** ដើម្បីធ្វើដូច្នេះបាន ភាគីម្ខាងត្រូវតែដាក់សំណើជាលាយល័ក្ខណ៍អក្សរទៅក្រឡាបញ្ជីតុលាការ មុន ឬនៅពេលជំនុំជម្រះ។

7. បញ្ហាផ្សេងទៀតដែលទាក់ទងនឹងសំណុំរឿងនេះ រួមទាំងការចូលរួមកម្មវិធីអប់រំមាតា/បិតា ការធ្វើតេស្ត DNA បញ្ជាក់ឪពុក/ម្ដាយ ការស្វែងរកការងារ។ ការចាត់តាំងអាណាព្យាបាលតំណាងឲ្យកូន និងការវាយតម្លៃផ្នែកចិត្តសាស្ត្រ។

អង្គចៅក្រមនឹងចេញសេចក្ដីបង្គាប់លើសំណុំរឿងបន្ទាប់ពីការជំនុំជម្រះដែលនឹងកំណត់រយៈពេលនៃចំណាត់ការ ហើយអាចនឹងចេញសេចក្ដីបង្គាប់ផ្សេងទៀត ដូចជាសេចក្ដីបង្គាប់បណ្ដោះអាសន្ន ឬសេចក្ដីបង្គាប់មួយដែលអនុវត្តកាតព្វកិច្ចផ្ដល់ប្រាក់ឧបត្ថម្ភកូន។

ការព្រមាន

**បើអ្នកគឺជាភាគីឆ្លើយតប និងមានបំណងជំទាស់នឹងពាក្យបណ្ដឹង ឬសំណើសុំ ការឆ្លើយតបត្រូវតែដាក់ក្នុងរយៈពេលកំណត់តាមច្បាប់ ឬវិធានតុលាការ។ សូមកុំរង់ចាំរហូតដល់ពេលជំនុំជម្រះ ក្នុងការបញ្ជាក់ការជំទាស់របស់អ្នក។**

**អ្នកមានសិទ្ធិបង្ហាញខ្លួន និងទទួលការកាត់ក្ដីនៅគ្រប់តុលាការទាំងអស់ (ការកាត់ក្ដី សវនាការ ការជំនុំជម្រះ ការសម្រុះសម្រួល)។ បើអ្នកខកខានមិនបានបង្ហាញខ្លួននៅសវនាការណាមួយ ឬទាំងអស់របស់តុលាការដោយគ្មានមូលហេតុសមស្រប តុលាការអាចនឹងចាត់វិធានការលើសំណុំរឿងរបស់អ្នក បើទោះបីជាអ្នកមិនមានវត្តមាននៅទីនោះក៏ដោយ។ នេះមានន័យថាតុលាការអាចនឹងចេញសេចក្ដីបង្គាប់បណ្ដោះអាសន្ន/កាលិកដោយកំបាំងមុខអ្នក ឬបើកសវនាការចុងក្រោយ ឬចេញសេចក្ដីបង្គាប់/សាលក្រមកំបាំងមុខ ទាក់ទងនឹងបញ្ហាណាមួយ ឬទាំងអស់នៅក្នុងសំណុំរឿងរបស់អ្នក ដោយរួមទាំងតែមិនកំណត់ត្រឹមតែភាពជាឪពុកម្ដាយ ឬ ភាពជាមេបា ឬ សិទ្ធិ និងទំនួលខុសត្រូវរបស់មេបាសម្រាប់កូន (សិទ្ធិចិញ្ចឹមកូន កន្លែងរស់នៅ សិទ្ធិសួរសុខទុក្ខ។ល។) ប្រាក់ឧបត្ថម្ភកូន ប្រាក់ឧបត្ថម្ភសហព័ទ្ធ (ប្ដី/ប្រពន្ធ)/អាហារកិច្ចថ្លៃមេធាវី និងការបែងចែកទ្រព្យសម្បត្តិរួមនិងមិនមែនរួម (បំណុល អចលនទ្រព្យ យានយន្ត ប្រាក់សោធននិវត្តន៍ គណនីចូលនិវត្តន៍។ល។) តុលាការក៏មានជម្រើសច្រានចោលការឆ្លើយតបណាមួយដែលអ្នកបានដាក់ទៅតុលាការ បើអ្នកមិនបានបង្ហាញខ្លួន។**